**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៣០៣ អនក្រ.បក

**អនុក្រឹត្យ**
**ស្តីពី**
**ការរៀបចំ និងការប្រព្រឹត្តទៅ**
**នៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ នៃក្រសួងមហាផ្ទៃ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៣៩ អនក្រ.បក ចុះថ្ងៃ២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា៩ មាត្រា១០ មាត្រា៤២ និងមាត្រា៤៥ នៃអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**
**ជំពូកទី១**
**បទប្បញ្ញត្តិទូទៅ**

**មាត្រា១._**

អគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ២៧៩ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ ត្រូវបានបង្កើត និងកែសម្រួលរចនាសម្ព័ន្ធឡើងវិញ ព្រមទាំងកំណត់តួនាទីភារកិច្ចនៅក្នុងអនុក្រឹត្យនេះ។

## ជំពូកទី២

## តួនាទីភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា២._**

អគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ មានតួនាទីភារកិច្ចធ្វើជាសេនាធិការជូនក្រសួងមហាផ្ទៃ ក្នុងការដឹកនាំ គ្រប់គ្រង សម្របសម្រួលគោលនយោបាយ អភិបាលកិច្ច ហេដ្ឋារចនាសម្ព័ន្ធ សុវត្ថិភាព បច្ចេកវិទ្យាឌីជីថល ការងារបណ្តុះបណ្តាល ស្រាវជ្រាវ នវានុវត្តន៍ និងផ្សព្វផ្សាយអប់រំ ពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាឌីជីថល លើកលែងតែវិស័យបច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មានវិទ្យាពាក់ព័ន្ធនឹងវិស័យសន្តិសុខជាតិ និងវិស័យដែលស្ថិតក្រោមសមត្ថកិច្ចនៃមជ្ឈមណ្ឌលជាតិបច្ចេកវិទ្យាព័ត៌មាន។

**មាត្រា៣._**

អគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- សហការរៀបចំសេចក្តីព្រាងច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្ត ដើម្បីធានាដល់ការគ្រប់គ្រង ការអភិវឌ្ឍ ការការពារសន្តិសុខ និងការទប់ស្កាត់បទល្មើសបច្ចេកវិទ្យា
- រៀបចំ គ្រប់គ្រង តាមដាន និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាឌីជីថលរបស់ក្រសួងមហាផ្ទៃ
- សហការ សម្របសម្រួល និងដឹកនាំអនុវត្តគម្រោងបច្ចេកវិទ្យាឌីជីថល សម្រាប់ការផ្តល់សេវាសាធារណៈ ការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធឌីជីថល ប្រព័ន្ធការងាររដ្ឋបាល និងជំនាញ ដើម្បីជំរុញការធ្វើទំនើបកម្ម និងបរិវត្តកម្មឌីជីថលក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ
- រៀបចំបទដ្ឋានបច្ចេកទេសនៃសម្ភារបច្ចេកវិទ្យា ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់ឱ្យអង្គភាព និងភាគីពាក់ព័ន្ធយកទៅអនុវត្ត
- សហការ ត្រួតពិនិត្យ វាយតម្លៃ លើការងារផ្គត់ផ្គង់ និងបំពាក់សម្ភារឧបករណ៍បច្ចេកទេស ព្រមទាំងប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- សហការ វាយតម្លៃ កំណត់អាទិភាព និងលើកយោបល់គម្រោងវិនិយោគវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន របស់ក្រសួងមហាផ្ទៃ និងអង្គភាពក្រោមចំណុះ
- ទទួលខុសត្រូវលើការអភិវឌ្ឍ ការធ្វើទំនើបកម្ម និងការថែទាំប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា និងមជ្ឈមណ្ឌលទិន្នន័យនៅទីស្តីការក្រសួងមហាផ្ទៃ
- គ្រប់គ្រង តភ្ជាប់ និងចែករំលែកផ្លាស់ប្តូរទិន្នន័យឌីជីថលក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ និងសេវាបច្ចេកវិទ្យា ដើម្បីឱ្យស្របតាមច្បាប់ បទដ្ឋានគតិយុត្ត និងគោលការណ៍សុវត្ថិភាពបច្ចេកវិទ្យា

- គ្រប់គ្រងការធ្វើសមាហរណកម្មតភ្ជាប់រវាងប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានរបស់ក្រសួងមហាផ្ទៃ ជាមួយប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាននៃបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា
- សិក្សា ស្រាវជ្រាវ និងនវានុវត្តន៍បច្ចេកវិទ្យាឌីជីថល ស្របតាមនិន្នាការបច្ចេកវិទ្យាថ្នាក់ជាតិ និងសកល ដើម្បីធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាសាធារណៈ កិច្ចការងាររដ្ឋបាល និងជំនាញ
- សហការបណ្តុះបណ្តាល និងផ្សព្វផ្សាយបញ្ជ្រាបចំណេះដឹង អំពីបច្ចេកវិទ្យាឌីជីថល សន្តិសុខសាយប័រ សម្រាប់អង្គភាពចំណុះក្រសួងមហាផ្ទៃទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឬស្ថាប័នពាក់ព័ន្ធផ្សេងទៀត
- សហការលើការងារគ្រប់គ្រង ថែទាំ និងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពបច្ចេកវិទ្យាឌីជីថលរបស់ក្រសួងមហាផ្ទៃ និងអង្គភាពចំណុះទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- សហការជាមួយនឹងអង្គភាពពាក់ព័ន្ធក្នុងការចាត់វិធានការដោះស្រាយ និងឆ្លើយតបលើបញ្ហាសន្តិសុខសាយប័រ ការវាយប្រហារប្រព័ន្ធព័ត៌មាន និងបច្ចេកវិទ្យាឌីជីថល
- សហការជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីរួមចំណែកក្នុងការបង្ការទប់ស្កាត់បទល្មើសបច្ចេកវិទ្យា
- ទទួលខុសត្រូវលើការងារទំនាក់ទំនង សហប្រតិបត្តិការជាមួយស្ថាប័នជាតិ អន្តរជាតិ និងអង្គភាពពាក់ព័ន្ធ ដើម្បីជំរុញការអភិវឌ្ឍ និងការធ្វើបរិវត្តកម្មឌីជីថលក្រសួងមហាផ្ទៃ
- សហការគ្រប់គ្រង តភ្ជាប់ ថែទាំ និងអភិវឌ្ឍ ប្រព័ន្ធវីដេអូសន្និសីទរបស់ក្រសួងមហាផ្ទៃ និងអង្គភាពចំណុះទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- គ្រប់គ្រង ត្រួតពិនិត្យ តាមដានខ្លឹមសារព័ត៌មាន អភិវឌ្ឍន៍ និងការពារសុវត្ថិភាពប្រព័ន្ធផ្សព្វផ្សាយឌីជីថលរបស់ក្រសួងមហាផ្ទៃ
- ធ្វើការផ្សព្វផ្សាយរូបភាព និងសកម្មភាព សមិទ្ធផល ព្រមទាំងស្នាដៃនានារបស់រាជរដ្ឋាភិបាល ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ស្ថាប័ននានា និងអាជ្ញាធរថ្នាក់ក្រោមជាតិ
- ទទួលខុសត្រូវលើដំណើរការស្ថានីយ៍វិទ្យុ និងទូរទស្សន៍មហាផ្ទៃ
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងទិសដៅបន្តរបស់អគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ តាមការកំណត់ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- អនុវត្តភារកិច្ច និងសិទ្ធិផ្សេងៗទៀត ដែលរដ្ឋមន្ត្រីក្រសួងមហាផ្ទៃប្រគល់ឱ្យ។

**មាត្រា៤._**

អគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ ដឹកនាំដោយអគ្គនាយក ០១(មួយ)រូប និងមានអគ្គនាយករង មួយចំនួនជាជំនួយតាមការចាំបាច់។

**មាត្រា៥._**

ត្រូវបានផ្ទេរនាយកដ្ឋានព័ត៌មានវិទ្យាពីអគ្គលេខាធិការដ្ឋាន និងផ្ទេរនាយកដ្ឋានផ្សព្វផ្សាយអប់រំ និងស្ថានីយ៍វិទ្យុ និងទូរទស្សន៍មហាផ្ទៃ ពីអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ មកចំណុះអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ។

**មាត្រា៦._**

អគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ មាននាយកដ្ឋានក្រោមឱវាទ ចំនួន ០៦ (ប្រាំមួយ) និងស្ថានីយ៍ចំនួន ០១(មួយ) ដូចខាងក្រោម៖

១- នាយកដ្ឋានរដ្ឋបាល-សរុប

២- នាយកដ្ឋានបណ្តុះបណ្តាល និងអភិបាលកិច្ចបច្ចេកវិទ្យាឌីជីថល

៣- នាយកដ្ឋានអភិវឌ្ឍកម្មវិធី និងនវានុវត្តន៍ឌីជីថល

៤- នាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

៥- នាយកដ្ឋានការពារសុវត្ថិភាពបច្ចេកវិទ្យាឌីជីថល

៦- នាយកដ្ឋានផ្សព្វផ្សាយអប់រំ

៧- ស្ថានីយ៍វិទ្យុ និងទូរទស្សន៍មហាផ្ទៃ (ថ្នាក់ស្មើនាយកដ្ឋាន) ។

នាយកដ្ឋាននីមួយៗ និងស្ថានីយ៍ ដឹកនាំដោយប្រធាន ០១(មួយ)រូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អង្គការលេខរបស់អគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ ត្រូវកំណត់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះឱ្យនាយកដ្ឋានទាំង០៦ និងស្ថានីយ៍០១ នៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ ត្រូវបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា៧._**

អគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ មាននិមិត្តសញ្ញា និងត្រាដោយឡែកសម្រាប់ប្រើប្រាស់ជាផ្លូវការក្នុងការបំពេញភារកិច្ចរបស់ខ្លួន។

**មាត្រា៨._**

នាយកដ្ឋានរដ្ឋបាល-សរុប មានតួនាទីធ្វើជាសេនាធិការជូនអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ ដែលមានភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងត្រា និងចាត់ចែងលិខិតស្នាមរដ្ឋបាលចេញ ចូល ការងាររបៀប និងឯកសារផ្សេងៗទៀតរបស់អគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ
- រៀបចំកសាងផែនការអំពីតម្រូវការមធ្យោបាយ និងសម្ភាររបស់អគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ
- គ្រប់គ្រងមធ្យោបាយ សម្ភារ ថវិកា បុគ្គលិក បញ្ជីសារពើភ័ណ្ឌ ចលនទ្រព្យ និងអចលនទ្រព្យរបស់អគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ
- គ្រប់គ្រង តាមដាន និងជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល លើការងារគ្រប់គ្រងលំហូរឯកសារ សម្ភារ ថវិកា បុគ្គលិក បញ្ជីសារពើភ័ណ្ឌ ចលនទ្រព្យ និងអចលនទ្រព្យរបស់អគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ

- រៀបចំ បូកសរុបផែនការសកម្មភាព និងផែនការថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងទិសដៅបន្តរបស់នាយកដ្ឋានរដ្ឋបាល-សរុប តាមការកំណត់ជូនអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ
- អនុវត្តភារកិច្ច និងសិទ្ធិផ្សេងៗទៀតដែលអគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ ប្រគល់ឱ្យ។

**មាត្រា៩._**

នាយកដ្ឋានបណ្តុះបណ្តាល និងអភិបាលកិច្ចបច្ចេកវិទ្យាឌីជីថល មានតួនាទីធ្វើជាសេនាធិការជូនអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ ដែលមានភារកិច្ចដូចខាងក្រោម៖

- សហការដឹកនាំ រៀបចំបទដ្ឋានសមត្ថភាព និងផែនទីបង្ហាញផ្លូវអភិវឌ្ឍជំនាញឌីជីថលក្របខ័ណ្ឌក្រសួងមហាផ្ទៃ
- រៀបចំផែនការបណ្តុះបណ្តាលអភិវឌ្ឍជំនាញបច្ចេកទេស បម្រើដល់ការងារអនុវត្តផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាឌីជីថល ការងារបរិវត្តកម្ម និងរដ្ឋាភិបាលឌីជីថលតាមបណ្តាអង្គភាពចំណុះក្រសួងមហាផ្ទៃ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- សហការ ដឹកនាំ និងរៀបចំការងារបណ្តុះបណ្តាលវគ្គខ្លីៗ(តិចជាង១ខែ) ជំនាញបច្ចេកទេសបម្រើដល់ការងារអនុវត្តផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាឌីជីថល ការងារបរិវត្តកម្ម និងរដ្ឋាភិបាលឌីជីថលតាមបណ្តាអង្គភាពចំណុះក្រសួងមហាផ្ទៃ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ដឹកនាំការស្រាវជ្រាវ និងនវានុវត្តន៍ បម្រើដល់ការបណ្តុះបណ្តាលមូលធនមនុស្ស គាំទ្រដល់ការរៀបចំ និងការអនុវត្តផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាឌីជីថល ការងារបរិវត្តកម្ម និងរដ្ឋាភិបាលឌីជីថលក្របខ័ណ្ឌក្រសួងមហាផ្ទៃ ប្រកបដោយប្រសិទ្ធភាព
- សហការ ដឹកនាំ រៀបចំ តាមដាន និងវាយតម្លៃកម្រិតសមត្ថភាពជំនាញឌីជីថលរបស់មន្ត្រីតាមបណ្តាអង្គភាពចំណុះក្រសួងមហាផ្ទៃ និងធ្វើការរៀបចំផែនការបណ្តុះបណ្តាលបំពេញបន្ថែមលើចំណេះជំនាញបច្ចេកទេស បម្រើដល់ការងារអនុវត្តផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាឌីជីថល ការងារបរិវត្តកម្ម និងរដ្ឋាភិបាលឌីជីថល ក្របខ័ណ្ឌក្រសួងមហាផ្ទៃ
- ផ្តល់ការប្រឹក្សាលើការងារបណ្តុះបណ្តាលធនធានមនុស្សផ្នែកបច្ចេកវិទ្យាឌីជីថល ដល់បណ្តាអង្គភាពចំណុះក្រសួងមហាផ្ទៃ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- សហការជាមួយអង្គភាពពាក់ព័ន្ធ ក្រសួងស្ថាប័នជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានាលើការងារបណ្តុះបណ្តាលបច្ចេកវិទ្យាឌីជីថល ស្របតាមផែនការនិងយុទ្ធសាស្ត្រដែលបានដាក់ជូន
- ដឹកនាំ រៀបចំ សម្របសម្រួល តាមដាន និងផ្តល់ប្រឹក្សាលើការអនុវត្តផែនការរដ្ឋាភិបាលឌីជីថល និងការធ្វើបរិវត្តកម្មឌីជីថល តាមបណ្តាអង្គភាពចំណុះក្រសួងមហាផ្ទៃទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ដឹកនាំ សម្របសម្រួល និងសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធជាតិ និងអន្តរជាតិលើការងារអនុវត្តផែនការរដ្ឋាភិបាលឌីជីថល និងបរិវត្តកម្មឌីជីថល

- រៀបចំ គ្រប់គ្រង តាមដាន និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាឌីជីថល ក្រសួងមហាផ្ទៃ
- ដឹកនាំ និងរៀបចំបង្កើតគោលនយោបាយបច្ចេកវិទ្យាឌីជីថលក្របខ័ណ្ឌក្រសួងមហាផ្ទៃ
- ពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយឌីជីថល តាមបណ្ដាអង្គភាពចំណុះក្រសួងមហាផ្ទៃ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- សហការ រៀបចំ បង្កើត និងវាយតម្លៃការអនុវត្តបទដ្ឋាន នីតិវិធីប្រតិបត្តិ និងការណែនាំស្ដីពីបច្ចេកវិទ្យាឌីជីថល ដល់បណ្ដាអង្គភាពចំណុះក្រសួងមហាផ្ទៃទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- រៀបចំបទដ្ឋានបច្ចេកទេសនៃសម្ភារបច្ចេកវិទ្យា ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់ឱ្យអង្គភាពចំណុះក្រសួងមហាផ្ទៃយកទៅអនុវត្ត
- សហការ ត្រួតពិនិត្យ វាយតម្លៃលើការងារផ្គត់ផ្គង់ និងបំពាក់សម្ភារឧបករណ៍បច្ចេកទេស ព្រមទាំងប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន សម្រាប់បម្រើឱ្យការបង្កើតប្រព័ន្ធបច្ចេកវិទ្យាឌីជីថលរបស់ក្រសួងមហាផ្ទៃ ស្របតាមច្បាប់ បទដ្ឋានគតិយុត្ត និងគោលការណ៍សុវត្ថិភាពបច្ចេកវិទ្យា
- សហការវាយតម្លៃ កំណត់អាទិភាព និងលើកយោបល់គម្រោងវិនិយោគវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានរបស់ក្រសួងមហាផ្ទៃ និងអង្គភាពក្រោមចំណុះ
- ដឹកនាំការស្រាវជ្រាវ និងនវានុវត្តន៍ បម្រើដល់គោលនយោបាយ និងអភិបាលកិច្ចបច្ចេកវិទ្យាឌីជីថល
- សហការជាមួយក្រសួងស្ថាប័នជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានាលើការងាររៀបចំគោលនយោបាយ និងអភិបាលកិច្ចបច្ចេកវិទ្យាឌីជីថល
- រៀបចំផែនការសកម្មភាព និងផែនការថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងទិសដៅបន្តរបស់នាយកដ្ឋានបណ្ដុះបណ្ដាល និងអភិបាលកិច្ចបច្ចេកវិទ្យាឌីជីថល តាមការកំណត់ជូនអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ
- អនុវត្តភារកិច្ច និងសិទ្ធិផ្សេងៗទៀតដែលអគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ ប្រគល់ឱ្យ។

**មាត្រា១០._**

នាយកដ្ឋានអភិវឌ្ឍកម្មវិធី និងនវានុវត្តន៍ឌីជីថល មានតួនាទីធ្វើជាសេនាធិការជូនអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ ដែលមានភារកិច្ចដូចខាងក្រោម៖

- រៀបចំយន្តការ ផែនការសិក្សាស្រាវជ្រាវ អភិវឌ្ឍ និងនវានុវត្តន៍បច្ចេកវិទ្យាឌីជីថល
- រៀបចំយន្តការ គ្រប់គ្រង និងវិភាគទិន្នន័យបម្រើដល់ការងារបង្កើនប្រសិទ្ធភាពសេវាសាធារណៈ កិច្ចការរដ្ឋបាល និងជំនាញ តាមបណ្ដាអង្គភាពចំណុះក្រសួងមហាផ្ទៃ

- គ្រប់គ្រង សម្របសម្រួល ការងារសិក្សាស្រាវជ្រាវ ការងារអភិវឌ្ឍន៍ និងនវានុវត្តន៍បច្ចេកវិទ្យាឌីជីថល ដើម្បីជំរុញការធ្វើទំនើបកម្ម ការធ្វើបរិវត្តកម្មឌីជីថលលើសេវាសាធារណៈ កិច្ចការរដ្ឋបាល និងជំនាញតាមបណ្តាអង្គភាពចំណុះក្រសួងមហាផ្ទៃ
- អភិវឌ្ឍន៍កម្មវិធីសូហ្វវែរបម្រើដល់ការទំនើបកម្ម ការធ្វើបរិវត្តកម្មឌីជីថលលើសេវាសាធារណៈ កិច្ចការរដ្ឋបាល និងជំនាញ តាមបណ្តាអង្គភាពចំណុះក្រសួងមហាផ្ទៃ
- ទទួលខុសត្រូវក្នុងការធ្វើបច្ចុប្បន្នភាព ការងារថែទាំ និងការងារទំនើបកម្មកម្មវិធីបច្ចេកវិទ្យាឌីជីថល ព្រមទាំងសុវត្ថិភាពទិន្នន័យឌីជីថលរបស់ក្រសួងមហាផ្ទៃ
- សហការជាមួយក្រសួងស្ថាប័នជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានាលើការងារស្រាវជ្រាវ អភិវឌ្ឍ និងនវានុវត្តន៍ឌីជីថល
- រៀបចំផែនការសកម្មភាព និងផែនការថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងទិសដៅបន្តរបស់នាយកដ្ឋានអភិវឌ្ឍកម្មវិធី និងនវានុវត្តន៍ឌីជីថល តាមការកំណត់ជូនអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ
- អនុវត្តភារកិច្ច និងសិទ្ធិផ្សេងៗទៀតដែលអគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ ប្រគល់ឱ្យ។

**មាត្រា១១._**

នាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន មានតួនាទីធ្វើជាសេនាធិការជូនអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ ដែលមានភារកិច្ចដូចខាងក្រោម៖

- សហការ អភិវឌ្ឍន៍ ធ្វើទំនើបកម្ម ថែទាំហេដ្ឋារចនាសម្ព័ន្ធឌីជីថល បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានក្រសួងមហាផ្ទៃ និងបណ្តាអង្គភាពចំណុះក្រសួងមហាផ្ទៃ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- គ្រប់គ្រងការងារតម្លើង ថែទាំ ធ្វើទំនើបកម្ម មជ្ឈមណ្ឌលទិន្នន័យ មណ្ឌលប្រតិបត្តិការបណ្តាញចំណុះក្រសួងមហាផ្ទៃ
- សហការលើការងារអភិវឌ្ឍ ការងារធ្វើទំនើបកម្ម ការងារថែទាំ ប្រព័ន្ធបច្ចេកវិទ្យា សារអេឡិចត្រូនិក ប្រព័ន្ធការពារសុវត្ថិភាពទិន្នន័យ ប្រព័ន្ធគ្រប់គ្រងបណ្តាញហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានក្រសួងមហាផ្ទៃ និងអង្គភាពក្រោមចំណុះ
- គ្រប់គ្រងការងារតភ្ជាប់បណ្តាញអ៊ីនធឺណិត អាសយដ្ឋានអាយភី ដល់ទីស្តីការក្រសួងមហាផ្ទៃ និងអង្គភាពក្រោមចំណុះក្រសួងមហាផ្ទៃ
- គ្រប់គ្រង សម្របសម្រួល ការប្រើប្រាស់ឈ្មោះដែនជាតិជូនក្រសួងមហាផ្ទៃ និងអង្គភាពក្រោមចំណុះ
- ដឹកនាំសម្របសម្រួលការតភ្ជាប់ ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ថ្នាលផ្លាស់ប្តូរទិន្នន័យជាតិតាមបណ្តាអង្គភាពក្រោមចំណុះក្រសួងមហាផ្ទៃ ទៅកាន់ក្រសួងស្ថាប័នរដ្ឋ និងឯកជន

- សហការគ្រប់គ្រងសម្ភារបច្ចេកវិទ្យាឌីជីថល ផ្តល់សេវាថែទាំបច្ចេកទេស នៅទីស្តីការក្រសួងមហាផ្ទៃ និងតាមបណ្តាអង្គភាពក្រោមចំណុះ
- ដឹកនាំការស្រាវជ្រាវ និងនវានុវត្តន៍ បម្រើដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- សហការជាមួយក្រសួង ស្ថាប័នជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានាលើការងារហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- រៀបចំផែនការសកម្មភាព និងផែនការថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងទិសដៅបន្តរបស់នាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន តាមការកំណត់ជូនអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ
- អនុវត្តភារកិច្ច និងសិទ្ធិផ្សេងៗទៀតដែលអគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ ប្រគល់ឱ្យ។

**មាត្រា១២._**

នាយកដ្ឋានការពារសុវត្ថិភាពបច្ចេកវិទ្យាឌីជីថល មានតួនាទីធ្វើជាសេនាធិការជូនអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ ដែលមានភារកិច្ចដូចខាងក្រោម៖

- សហការ រៀបចំគោលនយោបាយ ស្តង់ដារ បទដ្ឋាន និងគោលការណ៍ណែនាំស្តីពីការគ្រប់គ្រង ហានិភ័យបច្ចេកវិទ្យា សន្តិសុខសាយប័រ សម្រាប់បណ្តាអង្គភាពចំណុះក្រសួងមហាផ្ទៃទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- សិក្សា ស្រាវជ្រាវ រៀបចំយុទ្ធសាស្ត្រក្នុងការពង្រឹងប្រសិទ្ធភាព និងការអនុវត្ត កិច្ចការពារសុវត្ថិភាពបច្ចេកវិទ្យាឌីជីថល ក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ
- សហការជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធក្នុងការបញ្ជ្រាបចំណេះដឹង ស្តីពីសន្តិសុខសាយប័រ និងបទល្មើសបច្ចេកវិទ្យាឌីជីថល
- សហការ ពិនិត្យ តាមដាន វាយតម្លៃការអនុវត្តគោលនយោបាយ បទដ្ឋាន និងគោលការណ៍ណែនាំពាក់ព័ន្ធការគ្រប់គ្រងសុវត្ថិភាព ហានិភ័យបច្ចេកវិទ្យាឌីជីថល និងសន្តិសុខសាយប័រ តាមបណ្តាអង្គភាពចំណុះក្រសួងមហាផ្ទៃទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- សហការ ពិនិត្យ និងវាយតម្លៃសុវត្ថិភាពប្រព័ន្ធកម្មវិធី ប្រព័ន្ធទិន្នន័យ បណ្តាញហេដ្ឋារចនាសម្ព័ន្ធ មជ្ឈមណ្ឌលទិន្នន័យ ឧបករណ៍បច្ចេកវិទ្យា និងម៉ាស៊ីនមេ តាមបណ្តាអង្គភាពចំណុះក្រសួងមហាផ្ទៃ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- សហការ អភិវឌ្ឍន៍ គ្រប់គ្រង ថែទាំ ប្រព័ន្ធការពារសុវត្ថិភាពបច្ចេកវិទ្យាឌីជីថលរបស់ក្រសួងមហាផ្ទៃ និងអង្គភាពចំណុះទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- សហការធ្វើការឆ្លើយតបឧប្បត្តិហេតុពាក់ព័ន្ធនឹងសុវត្ថិភាពបច្ចេកវិទ្យាឌីជីថល ក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ
- សហការជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីរួមចំណែកក្នុងការបង្ការទប់ស្កាត់បទល្មើសបច្ចេកវិទ្យា

- រៀបចំផែនការសកម្មភាពនិងផែនការថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងទិសដៅបន្តរបស់នាយកដ្ឋានការពារសុវត្ថិភាពបច្ចេកវិទ្យាឌីជីថល តាមការកំណត់ជូនអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ
- អនុវត្តភារកិច្ច និងសិទ្ធិផ្សេងៗទៀតដែលអគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ ប្រគល់ឱ្យ។

**មាត្រា១៣.**_

នាយកដ្ឋានផ្សព្វផ្សាយអប់រំ មានតួនាទីធ្វើជាសេនាធិការជូនអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ ដែលមានភារកិច្ចដូចខាងក្រោម៖

- កសាងផែនការ សកម្មភាពរយៈពេលវែង-ខ្លី និងចាត់ចែងអនុវត្តការងារអប់រំសតិអារម្មណ៍ក្នុងស្រទាប់មហាជនទូទៅ ដែលបម្រើឱ្យកិច្ចប្រតិបត្តិការគ្រប់មុខជំនាញរបស់កងកម្លាំងនគរបាលជាតិ តាមការវិវឌ្ឍរបស់ប្រទេសជាតិ
- រៀបចំផ្សព្វផ្សាយព័ត៌មានតាមរយៈទស្សនាវដ្ដី នាទីសន្តិសុខមាតុភូមិ និងគេហទំព័រពីសមិទ្ធផលនានា និងការវិវឌ្ឍរីកចម្រើនលើគ្រប់វិស័យរបស់សង្គមជាតិ ដែលឆ្លុះបញ្ចាំងពីសកម្មភាព និងស្នាដៃរបស់រាជរដ្ឋាភិបាល ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ កងកម្លាំងនគរបាលជាតិគ្រប់ជំនាញ មន្ត្រីរាជការស៊ីវិល មន្ត្រីពន្ធនាគារ ការងារស្ថាប័ននានា និងអាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ស្របទៅតាមវិជ្ជាជីវៈសារព័ត៌មាន
- សម្របសម្រួល និងទំនាក់ទំនងជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ អគ្គនាយកដ្ឋានពាក់ព័ន្ធជំនាញវិជ្ជាជីវៈសារព័ត៌មាន អង្គការជាតិ-អន្តរជាតិ ស្ថាប័នសារព័ត៌មានរដ្ឋ និងឯកជនទាំងក្នុងប្រទេស និងក្រៅប្រទេស និងសប្បុរជននានា ក្នុងការស្វែងរកជំនួយជាថវិកា ផ្នែកបច្ចេកទេស ឧបករណ៍ សម្ភារ បរិក្ខាផ្សេងៗ ដើម្បីផ្គត់ផ្គង់ និងជំរុញដល់វិស័យផ្សព្វផ្សាយព័ត៌មានរបស់ក្រសួងមហាផ្ទៃ
- សម្របសម្រួល និងទំនាក់ទំនងជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋាននានាចំណុះក្រសួងមហាផ្ទៃ ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ដើម្បីពង្រឹង និងពង្រីកសមត្ថភាពដល់មន្ត្រីជំនាញផ្សព្វផ្សាយអប់រំ ក្នុងការបំពាក់បំប៉នពាក់ព័ន្ធជំនាញវិជ្ជាជីវៈសារព័ត៌មាន និងបម្រើឱ្យការបង្ការ បង្ក្រាបគ្រប់សកម្មភាពបទល្មើស ឱ្យចំទិសដៅនិងមានប្រសិទ្ធភាព
- សម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងកសាងផែនការសិក្សា ស្រាវជ្រាវ ចងក្រងប្រមែប្រមូលនូវរាល់ឯកសារ លិខិតបទដ្ឋានគតិយុត្ត សមិទ្ធផល ស្នាដៃជាប្រវត្តិសាស្ត្រនានារបស់កងកម្លាំងនគរបាលជាតិកម្ពុជាគ្រប់សម័យ គ្រប់ជំនាន់ ដើម្បីរៀបចំថែរក្សាទុកជាលក្ខណៈយូរអង្វែងក្នុងសារមន្ទីរនគរបាលជាតិ
- កសាងផែនការគ្រប់គ្រងរោងពុម្ព និងបោះពុម្ពនូវរាល់ឯកសារបម្រើផ្ទាល់ដល់ការងារគ្រប់គ្រងមុខជំនាញនគរបាលជាតិ និងផ្នែករដ្ឋបាលទូទៅនៃក្រសួងមហាផ្ទៃ ព្រមទាំងបោះពុម្ពកាសែត ទស្សនាវដ្ដី ឯកសារ និងសៀវភៅផ្សេងៗ



ឞ

- កសាងផែនការបណ្តុះបណ្តាល ហ្វឹកហ្វឺនបំពាក់បំប៉នមុខជំនាញវិជ្ជាជីវៈសារព័ត៌មានដល់មន្ត្រីនគរបាលបម្រើការងារផ្សព្វផ្សាយអប់រំនៃនាយកដ្ឋានផ្សព្វផ្សាយអប់រំ និងតាមបណ្តាស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត
- សម្របសម្រួល និងសហការជាមួយអគ្គលេខាធិការដ្ឋាន អគ្គស្នងការដ្ឋាននគរបាលជាតិ និងអគ្គនាយកដ្ឋាននានា ដើម្បីរៀបចំសកម្មភាពសមោសរ តុបតែងលម្អទីស្តីការក្រសួងក្នុងឱកាសព្រះរាជពិធីបុណ្យជាតិ អន្តរជាតិ និងអង្គពិធីផ្សេងៗ
- ដឹកនាំមន្ត្រីនគរបាលបម្រើការងារផ្សព្វផ្សាយអប់រំនៅនាយកដ្ឋានផ្សព្វផ្សាយអប់រំ និងមន្ត្រីជំនាញផ្សព្វផ្សាយអប់រំនៅតាមបណ្តាស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ដើម្បីអនុវត្តឱ្យបានត្រឹមត្រូវតាមមុខជំនាញវិជ្ជាជីវៈសារព័ត៌មាន
- គ្រប់គ្រង សហការ អនុវត្តការងារប្រមូល ផលិត ផ្សព្វផ្សាយ រក្សាទុកខ្លឹមសារព័ត៌មាន ឯកសារច្បាប់គតិយុត្ត អត្ថបទ រូបភាព និងវីដេអូ បម្រើដល់ការងារបញ្ជ្រាបចំណេះដឹង និងសារព័ត៌មានក្រសួងមហាផ្ទៃ
- តាមដានសារព័ត៌មានដែលពាក់ព័ន្ធនឹងដែនសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ ដើម្បីធ្វើការបកស្រាយបំភ្លឺ និងឆ្លើយតប
- ដឹកនាំ គ្រប់គ្រង ការងារវីដេអូសន្និសីទក្រសួងមហាផ្ទៃ និងសហការគាំទ្រដល់អង្គភាពចំណុះក្រសួងមហាផ្ទៃ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ទំនាក់ទំនង និងសហប្រតិបត្តិការជាមួយស្ថាប័នជាតិ អន្តរជាតិ អង្គភាពពាក់ព័ន្ធ ដើម្បីអភិវឌ្ឍវិស័យសារព័ត៌មាន ផ្សព្វផ្សាយឌីជីថល វីដេអូសន្និសីទ
- រៀបចំផែនការសកម្មភាព និងផែនការថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងទិសដៅបន្តរបស់នាយកដ្ឋានផ្សព្វផ្សាយអប់រំតាមការកំណត់ជូនអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ
- អនុវត្តភារកិច្ច និងសិទ្ធិផ្សេងៗទៀតដែលអគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ ប្រគល់ឱ្យ។

**មាត្រា១៤.-**

ស្ថានីយ៍វិទ្យុ និងទូរទស្សន៍មហាផ្ទៃ (ថ្នាក់ស្មើនាយកដ្ឋាន) មានតួនាទីធ្វើជាសេនាធិការជូនអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ ដែលមានភារកិច្ចដូចខាងក្រោម៖

- ផ្សព្វផ្សាយព័ត៌មាន ពីសមិទ្ធិផលនានានិងការវិវឌ្ឍរីកចម្រើនលើគ្រប់វិស័យរបស់សង្គមជាតិ ដែលឆ្លុះបញ្ចាំងពីសកម្មភាព និងស្នាដៃរបស់រាជរដ្ឋាភិបាល ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ស្ថាប័ននានា និងអាជ្ញាធរដែនដី
- ផ្សព្វផ្សាយព័ត៌មាន ពីសកម្មភាពប្រតិបត្តិការប្រចាំថ្ងៃរបស់កងកម្លាំងនគរបាលជាតិគ្រប់មុខជំនាញ និងសមត្ថកិច្ចជំនាញពាក់ព័ន្ធ ព្រមទាំងមហាជនទូទៅដែលរួមចំណែកធ្វើសហប្រតិបត្តិការបង្ការ បង្ក្រាបបទល្មើស គ្រប់ប្រភេទសំដៅថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គម

- ផ្សព្វផ្សាយច្បាប់ និងនូវរាល់បទបញ្ញា សារាចរ គោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃ
- បង្កើតកម្មវិធីស្វែងយល់ពីជំនាញនាទីសិល្បៈ អប់រំ កីឡា និងល្បែងកំសាន្តចូលរួមលើកកម្ពស់វិស័យវប្បធម៌ជាតិ ដើម្បីទទួលបានប្រជាប្រិយភាព
- រៀបចំគម្រោងផែនការផ្សព្វផ្សាយព័ត៌មានរយៈពេលវែង-ខ្លី ស្របតាមសភាពការណ៍វិវឌ្ឍន៍នៅក្នុងប្រទេស និងសកលលោក
- អនុវត្តតាមការប្រគល់ភារកិច្ចពីអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីល និងផ្សព្វផ្សាយអប់រំ ដើម្បីធ្វើការទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធ ស្វែងរកប្រភពព័ត៌មាន ដើម្បីផ្សព្វផ្សាយឱ្យបានទាន់ពេលវេលា
- ស្វែងរកដៃគូក្រុមហ៊ុនវិនិយោគនៅក្នុង ឬក្រៅប្រទេស ដើម្បីសហប្រតិបត្តិការលើការងារអភិវឌ្ឍន៍ បច្ចេកទេស និងដំណើរការធ្វើអាជីវកម្ម តាមដំណាក់កាលនីមួយៗ។ ការធ្វើអាជីវកម្មត្រូវមានកិច្ចសន្យាច្បាស់លាស់ដោយស្ថានីយ៍វិទ្យុ និងទូរទស្សន៍ ទទួលខុសត្រូវលើខ្លឹមសារនយោបាយ និងវិជ្ជាជីវៈ។ ចំពោះប្រភពមូលធនសម្រាប់ដំណើរការធ្វើអាជីវកម្ម គឺមិនស្ថិតក្នុងប្រភពផ្គត់ផ្គង់ពីថវិកាជាតិឡើយ
- ធ្វើកិច្ចសហការជាមួយស្ថានីយ៍ និងទូរទស្សន៍នានា ដើម្បីផ្លាស់ប្តូរបទពិសោធន៍ ពង្រីកបច្ចេកវិទ្យាបង្កើនគុណភាពផ្សព្វផ្សាយព័ត៌មានឱ្យកាន់តែទូលំទូលាយ
- កសាងគម្រោងផែនការបំពាក់ និងគ្រប់គ្រងថែរក្សា ឧបករណ៍ មធ្យោបាយ និងសម្ភារបច្ចេកទេស របស់អង្គភាព ដើម្បីធានាបានប្រសិទ្ធភាពការងារ
- កសាងគម្រោងផែនការបើកវគ្គបណ្តុះបណ្តាល ហ្វឹកហ្វឺន និងបំប៉នដល់មន្ត្រី បុគ្គលិក ដើម្បីបង្កើនកម្រិតយល់ដឹងពីសកម្មភាពថតរូបភាព ចុះយកព័ត៌មាន តែងនិពន្ធអត្ថបទតាមមុខវិជ្ជាជីវៈសារព័ត៌មាន
- ធ្វើការងារគ្រប់គ្រងឯកសារ ការងារបុគ្គលិក ភស្តុភារ និងគណនេយ្យរបស់ស្ថានីយ៍វិទ្យុ និងទូរទស្សន៍មហាផ្ទៃ តាមការកំណត់របស់ក្រសួង
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងទិសដៅបន្តរបស់ស្ថានីយ៍វិទ្យុ និងទូរទស្សន៍មហាផ្ទៃ តាមការកំណត់ជូនអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ
- អនុវត្តភារកិច្ច និងសិទ្ធិផ្សេងៗទៀតដែលអគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ ប្រគល់ឱ្យ។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**មាត្រា១៥._**

មាត្រា១៤ មាត្រា៦៧ និងមាត្រា៧១ នៃអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ អនុក្រឹត្យលេខ ២៧៩ អនក្រ.បក

ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយ អប់រំ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា១៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៤ រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែតុលា ឆ្នាំ២០២៣
**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ.....៣០៣.....អនក្រ.បក ចុះថ្ងៃទី..៣...ខែ....តុលា......ឆ្នាំ២០២៣

ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ នៃក្រសួងមហាផ្ទៃ

**អង្គការលេខរបស់អគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ**

